ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២០ សហវ.ប្រក

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
ចូល
លេខ 589
ថ្ងៃ 07.10.20 8h30
ម៉ោង

# ប្រកាសអន្តរក្រសួង

## ស្តីពី

## អត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១.-**

សម្បទានិក ដែលទទួលអាជ្ញាបណ្ណធនធានរ៉ែទាំងអស់ លើកលែងតែអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណកែច្នៃធនធានរ៉ែ (ហៅកាត់ថា "សម្បទានិក") ត្រូវបង់ជូនរដ្ឋ នូវសួយសារលើតម្លៃផលិតផលរ៉ែ (ឬហៅកាត់ថា "សួយសារ") ដែលទាញយកបាន ស្របតាមការកំណត់ក្នុងប្រកាសនេះ។

**ប្រការ ២.-**

អត្រាសួយសារ ត្រូវបានកំណត់ដូចខាងក្រោម÷

**ក./ ផលិតផលរ៉ែសំណង់ (គិតលើបរិមាណផលិតនៅអណ្ដូងរ៉ែ)**

| ល.រ | ផលិតផលរ៉ែ | អត្រាសួយសារ | មូលដ្ឋាន និងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ថ្មបំបែកគ្រប់ប្រភេទ | ១ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីតុណ | |
| ២ | ក្រួសក្រាវែល | ០,៨៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគីតុណ | |

| | | | |
|---|---|---|---|
| ៣ | ខ្សាច់ (ទន្លេ, ស្ទឹង, បឹង, ព្រែក, អូរ, សមុទ្រ) ខ្សាច់បក (ខ្សាច់សំណង់) និងដីល្បាយខ្សាច់ | ០,៧០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | |
| ៤ | ដីក្រហម (ឡាតេរីត) និង ខ្សាច់ភ្នំ | ០,២៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | |
| ៥ | ដីល្បាប់ ដីល្បាយដីឥដ្ឋ ដីឥដ្ឋ និងអាចម៍ដី | ០,១៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | |
| ៦ | ខ្សាច់សំណង់ និង ដីល្បាយខ្សាច់ ក្នុងគោលបំណងនាំចេញ | ២ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | |
| ៧ | ឡាតេរីតអារ | ៧ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | |
| ៨ | -ថ្មអារ (ប្លុក សម្រាប់ប្រើប្រាស់ក្នុងស្រុក)<br>-ថ្មអារ (សន្លឹកសម្រាប់ប្រើប្រាស់ក្នុងស្រុក និងនាំចេញ) | ៧០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ ក (Type A) |
| | | ៤៧ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ ខ (Type B) |
| | | ២៧ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ គ (Type C) |
| | | ១១ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ ឃ (Type D) |
| ៩ | ថ្មអារ (ប្លុក) ក្នុងគោលបំណងនាំចេញ | ២២៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ ក (Type A) |
| | | ១៤៥ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ ខ (Type B) |
| | | ៨០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ គ (Type C) |

| | | | |
|---|---|---|---|
| | | ៣០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រគ្រីគុណ | យថាប្រភេទ ឃ (Type D) |
| ១០ | ប៉ាហ្គោឌីត (ថ្មកែវ) | ២០ ដុល្លារអាមេរិក ក្នុងមួយតោន | |

ខ./ ផលិតផលរ៉ែឧស្សាហកម្ម

| ល.រ | ផលិតផលរ៉ែ | អត្រាសួយសារ | មូលដ្ឋាន និងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ធ្យូងថ្ម | ៧ ភាគរយ | គិតលើបរិមាណលក់លើទីផ្សារក្នុងករណីថ្លៃលក់ផលិតផលធ្យូងថ្មលើទីផ្សារ (Arm`s Length Price) ទាបជាង ១០០ ដុល្លារអាមេរិក/តោន |
| | | ៨,៥០ ភាគរយ | គិតលើបរិមាណលក់លើទីផ្សារក្នុងករណីថ្លៃលក់ផលិតផលធ្យូងថ្មលើទីផ្សារ (Arm`s Length Price) ពី ១០០ ទៅ ១៥០ ដុល្លារអាមេរិក/តោន |
| | | ១០ ភាគរយ | គិតលើបរិមាណលក់លើទីផ្សារក្នុងករណីថ្លៃលក់ផលិតផលធ្យូងថ្មលើទីផ្សារ (Arm`s Length Price) ខ្ពស់ជាង ១៥០ ដុល្លារអាមេរិក/តោន |
| ២ | ដីឥដ្ឋ កុល្លាភាជន៍ | ១០ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm`s Length Price) |
| ៣ | ថ្មកំបោរ និងដូឡូមីត (ប្រើប្រាស់ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម) | ០,៦០ ដុល្លារអាមេរិក ក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលស៊ីម៉ង់ត៍លើទីផ្សារ ទាបជាង ឬស្មើ ១៥០ ដុល្លារអាមេរិក/តោន |
| | | ០,៨០ ដុល្លារអាមេរិក ក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលស៊ីម៉ង់ត៍លើទីផ្សារ ខ្ពស់ជាង ១៥០ ដុល្លារអាមេរិក/តោន |

| | | | |
|---|---|---|---|
| ៤ | ថ្មកំបោរ (ប្រើប្រាស់ក្នុងវិស័យលោហស្សាហកម្ម) | ១,៥០ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលស៊ីម៉ង់ត៍លើទីផ្សារទាបជាង ឬស្មើ ១៥០ ដុល្លារអាមេរិក/តោន |
| | | ២ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលស៊ីម៉ង់ត៍លើទីផ្សារខ្ពស់ជាង ១៥០ ដុល្លារអាមេរិក/តោន |
| ៥ | ផូស្វាត | ១,៥០ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលជីផូស្វាតលើទីផ្សារទាបជាង ឬស្មើ ១០០ ដុល្លារអាមេរិក/តោន |
| | | ២ ដុល្លារអាមេរិកក្នុងមួយតោន | គិតលើបរិមាណផលិតផលរ៉ែនៅអណ្តូងរ៉ែក្នុងករណីថ្លៃមធ្យមនៃផលិតផលជីផូស្វាតលើទីផ្សារខ្ពស់ជាង ១០០ ដុល្លារអាមេរិក/តោន |
| ៦ | ខ្សាច់ស៊ីលីស | ៥ ដុល្លារអាមេរិកក្នុងមួយតោន | |
| ៧ | ខ្សាច់ស៊ីលីសក្នុងគោលបំណងនាំចេញ | ១០ ដុល្លារអាមេរិកក្នុងមួយតោន | |
| ៨ | ទឹកក្តៅក្រោមដីនិងទឹកខនិជ | ២ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm`s Length Price) |
| ៩ | បុកស៊ីត សម្រាប់ឧស្សាហកម្មក្នុងស្រុក | ៧,៥០ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm`s Length Price) |
| ១០ | បុកស៊ីត សម្រាប់នាំចេញ | ១០ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm`s Length Price) |

គ./ ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល

| ល.រ | ផលិតផលរ៉ែ | អត្រាសួយសារ | មូលដ្ឋាន និងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល (ចំពោះប្រភេទឧស្សាហកម្ម) | ១៥ ភាគរយ | នៃចំណូលដុលពីការលក់លើទីផ្សារ (Arm`s Length Price) |
| ២ | ត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងគុណភាពប្រហាក់ប្រហែល (ចំពោះការប្រកបអាជីវកម្មជាលក្ខណៈគ្រួសាររបស់ប្រជាពលរដ្ឋខ្មែរ) | ២ ០០០ ដុល្លារអាមេរិកក្នុងមួយហិកតា | ផ្ទៃក្រឡា ដែលធ្វើអាជីវកម្ម |

**ឃ./ ផលិតផលរ៉ែលោហៈ**

| ល.រ | ផលិតផលរ៉ែ | អត្រាសួយសារ | មូលដ្ឋាន និងលក្ខខណ្ឌសម្រាប់ការគណនា |
|---|---|---|---|
| ១ | ធនធានរ៉ែលោហៈ រួមទាំងលោហៈមានតម្លៃ លោហៈមូលដ្ឋាន លោហៈកម្រ និងប្រភេទប្រហាក់ប្រហែល | ៣ ភាគរយ | នៃចំណូលដុលពីការលក់លោហធាតុ (metals) លើទីផ្សារ (Arm`s Length Price) |
| | | ៦ ភាគរយ | នៃចំណូលដុលពីការលក់កំហាប់រ៉ែ (Concentrate) លើទីផ្សារ (Arm`s Length Price) |
| | | ៨ ភាគរយ | នៃចំណូលដុលពីការលក់រ៉ែឆៅ (Crude Ore) លើទីផ្សារ (Arm`s Length Price) |

សេចក្ដីលម្អិតអំពីការកំណត់លក្ខណៈនៃថ្មអារ ទៅតាមយថាប្រភេទនីមួយៗ ដូចមានចែងក្នុង ចំណុច (ក) ប្រការ ២ នៃប្រកាសនេះ នឹងត្រូវកំណត់ដោយប្រកាសក្រសួងរ៉ែ និងថាមពល។

**ប្រការ ៣.-**

អនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ចំណូលសួយសារត្រូវធ្វើការបែងចែក និងកត់ត្រាក្នុងខ្ទង់ចំណូល ដូចមានកំណត់ខាងក្រោម÷

**ក-ការបែងចែក និងការកត់ត្រាចំណូលសួយសារ៖**

ក.១-ចំណូលសួយសារលើតម្លៃផលិតផលរ៉ែ ដូចមានកំណត់ក្នុងប្រការ២ ចំណុច (ក) ត្រូវបែងចែកជា ៣ ផ្នែក រួមមាន÷

- ចំនួន ៤០% (សែសិបភាគរយ) នៃចំណូលសួយសារ ត្រូវបង់ និងកត់ត្រាក្នុងចំណូលរបស់ថ្នាក់ជាតិ។
- ចំនួន ៥០% (ហាសិបភាគរយ) នៃចំណូលសួយសារ ត្រូវបង់ និងកត់ត្រាក្នុងចំណូលរបស់ថ្នាក់ក្រោមជាតិ។
- ចំនួន ១០% (ដប់ភាគរយ) នៃចំណូលសួយសារ ត្រូវបង់ និងកត់ត្រាក្នុងចំណូលកាត់ទុក។

ក.២-ចំណូលសួយសារ ដូចមានកំណត់ក្នុងប្រការ២ ចំណុច (ខ) ចំណុច (គ) និងចំណុច (ឃ) ត្រូវបែងចែកជា២ផ្នែក រួមមាន÷

- ចំនួន ៩០% (កៅសិបភាគរយ) នៃចំណូលសួយសារ ត្រូវបង់ និងកត់ត្រាក្នុងចំណូលរបស់ថ្នាក់ជាតិ។
- ចំនួន ១០% (ដប់ភាគរយ) នៃចំណូលសួយសារ ត្រូវបង់ និងកត់ត្រាក្នុងចំណូលកាត់ទុក។

**ខ-បែបបទនៃការបង់ចំណូលសួយសារ៖**

- សម្បទានិកដែលមានកាតព្វកិច្ចត្រូវបង់ចំណូលសួយសារ ស្របតាមប្រការ១ នៃប្រកាសនេះ ត្រូវធ្វើការប្រកាសផែនការផលិតកម្ម និងប្រកាសសួយសារនៅក្រសួងរ៉ែ និងថាមពល (អគ្គនាយកដ្ឋានធនធានរ៉ែ) ឬមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ឱ្យបានមុនថ្ងៃទី១៥ នៃដើមត្រីមាសនីមួយៗ ដើម្បីទទួលយកលិខិតបញ្ជាបង់ប្រាក់ចំណូលសួយសារ។
- បន្ទាប់ពីទទួលលិខិតប្រកាសផែនការផលិតកម្មពីសម្បទានិក និងឯកសារពាក់ព័ន្ធផ្សេងៗ អំពីការបង់ចំណូលសួយសារ ក្រសួងរ៉ែ និងថាមពល (អគ្គនាយកដ្ឋានធនធានរ៉ែ) ឬមន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត ត្រូវចេញលិខិតបញ្ជាបង់ប្រាក់នៃចំណូលសួយសារនេះ ទៅធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជដៃគូ (រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល) ជូនសម្បទានិក។ លិខិតបញ្ជាបង់ប្រាក់ ត្រូវមានការបែងចែកច្បាស់លាស់ អំពីយថាប្រភេទនៃខ្ទង់ចំណូល ជាចំណូលថ្នាក់ជាតិ ចំណូលថ្នាក់ក្រោមជាតិ និងចំណូលកាត់ទុក ដូចមានចែងនៅក្នុងប្រការ៣ ចំណុច (ក) និងត្រូវមានការកំណត់កាលបរិច្ឆេទបង់ប្រាក់មិនឱ្យលើសពីថ្ងៃទី២០ នៃដើមត្រីមាសនីមួយៗ។ ករណីសម្បទានិក ប្រកាសក្រោយថ្ងៃទី១៥ ឬបង់ប្រាក់ក្រោយថ្ងៃទី២០ នៃដើមត្រីមាសនីមួយៗ ត្រូវទទួលរងការពិន័យស្មើនឹង ២% (ពីរភាគរយ) ក្នុងមួយខែ ដោយគិតតាមអត្រាការប្រាក់សមាសប្រចាំខែ។
- ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) អាចចេញលិខិតគ្រង់ជូនសម្បទានិក ឱ្យបង់ចំណូលនេះ ដោយមានបញ្ជាក់ច្បាស់លាស់ អំពីយថាប្រភេទខ្ទង់ចំណូល និងកាលបរិច្ឆេទបង់ប្រាក់ ទៅធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជដៃគូ (រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល) ជូនសម្បទានិក។
- បន្ទាប់ពីទទួលបានលិខិតបញ្ជាបង់ប្រាក់ចំណូលសួយសារ ពីក្រសួងរ៉ែនិងថាមពល (អគ្គនាយកដ្ឋានធនធានរ៉ែ) ឬពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) ឬមន្ទីររ៉ែ និង

ថាមពល រាជធានី-ខេត្ត សម្បទានិកត្រូវបង់ចំណូលសួយសារ ដោយបង់ត្រង់ចូលគណនីដែលមានកំណត់នៅក្នុងលិខិតបញ្ជាបង់ប្រាក់។

**គ-ការជូនព័ត៌មានស្តីពីការបង់ប្រាក់÷**

ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានបង់ប្រាក់ តាមលិខិតបញ្ជាបង់ប្រាក់ សម្បទានិកត្រូវផ្តល់បណ្ណបង់ប្រាក់ ឬប្រកាសឥណទាន ឬសក្ខីបត្រ ឬឯកសារប្រហាក់ប្រហែល។ល។ ជាច្បាប់ថតចម្លង ជូន÷

- ក្រសួងរ៉ែ និងថាមពល ចំនួន ១ (មួយ) ច្បាប់ ចំពោះសម្បទានិកបង់ប្រាក់ តាមលិខិតបញ្ជាបង់ប្រាក់ ដែលចេញដោយក្រសួងរ៉ែនិងថាមពល។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) ចំនួន១ (មួយ) ច្បាប់ ចំពោះសម្បទានិកបង់ប្រាក់ តាមលិខិតបញ្ជាបង់ប្រាក់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- មន្ទីររ៉ែនិងថាមពល និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្ត ចំនួន១ (មួយ) ច្បាប់ៗ ចំពោះសម្បទានិកបង់ប្រាក់ តាមលិខិតបញ្ជាបង់ប្រាក់ ចេញដោយមន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត។

**ប្រការ ៤.~**

ប្រាក់ចំណូលសួយសារ ត្រូវបង់ជាមុន ប្រចាំត្រីមាសនីមួយៗ ដូចខាងក្រោម÷

ក-ចំពោះសម្បទានិកជាប់កាតព្វកិច្ចបង់សួយសារ ត្រូវអនុវត្តតាមកាតព្វកិច្ចដូចមានចែងក្នុងចំណុច (ខ) ប្រការ ៣ នៃប្រកាសនេះ។

ខ-ករណីអាជ្ញាបណ្ណចេញថ្មី សម្បទានិកត្រូវដាក់ប្រកាសផែនការផលិតកម្ម និងបង់ប្រាក់រំដោះ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ ឬយ៉ាងហោច ១០ (ដប់) ថ្ងៃ មុនពេលចាប់ផ្តើមផលិតកម្មតាមផែនការផលិតកម្មដែលមានការឯកភាពពីក្រសួងរ៉ែនិងថាមពល។ ក្នុងករណីសម្បទានិកមិនបានបង់ប្រាក់រំដោះសួយសារ មុនពេលផលិតកម្មចាប់ផ្តើម សម្បទានិកត្រូវប្រឈមនឹងវិធានការផ្លូវច្បាប់ជាធរមាន។

គ-សម្បទានិកជាប់កាតព្វកិច្ចបង់សួយសារ ត្រូវប្រកាសថ្លៃសួយសារលើបរិមាណផលិតផលរ៉ែ ដែលបានផលិត ឬបានទាញយកជាក់ស្តែងរៀងរាល់ត្រីមាសនីមួយៗ និងត្រូវធ្វើការទូទាត់កាត់កង មុនកាលបរិច្ឆេទដាក់ប្រកាស និងបង់ប្រាក់រំដោះសម្រាប់ត្រីមាសបន្ទាប់ ដូចមានកំណត់នៅចំណុច (ខ) ប្រការ ៣ នៃប្រកាសនេះ និងស្របតាមលក្ខខណ្ឌ ដូចខាងក្រោម÷

គ.១-ចំពោះផលិតផលរ៉ែ ដូចមានកំណត់នៅចំណុច (ក) ប្រការ ២ នៃប្រកាសនេះ÷

គ.១.១-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការផលិតកម្មប្រចាំត្រីមាស តិចជាងថ្លៃសួយសារតាមបរិមាណដែលផលិត ឬទាញយកបានជាក់ស្តែងប្រចាំត្រីមាស នោះសម្បទានិកមានកាតព្វកិច្ចត្រូវបង់បង្គ្រប់។

គ.១.២-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការផលិតកម្មប្រចាំត្រីមាស ច្រើនជាងថ្លៃសួយសារតាមបរិមាណដែលផលិត ឬទាញយកបានជាក់ស្តែងប្រចាំត្រីមាស ហើយអាជ្ញាបណ្ណធនធានរ៉ែក៏នៅមាន

សុពលភាព នោះចំនួនប្រាក់រំដោះដែលបានបង់លើស មិនត្រូវបានអនុញ្ញាតឱ្យជាឥណទានប្ដូរយោងទៅត្រីមាសបន្ទាប់ឡើយ និងត្រូវចាត់ទុកជាប្រយោជន៍ថវិការដ្ឋ។

គ.១.៣-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការផលិតកម្មប្រចាំត្រីមាស ច្រើនជាងថ្លៃសួយសារតាមបរិមាណដែលផលិត ឬទាញយកបានជាក់ស្ដែងប្រចាំត្រីមាស ប៉ុន្តែអាជ្ញាបណ្ណត្រូវបានដកហូត ឬត្រូវបានបញ្ចប់ ឬត្រូវផុតសុពលភាព នោះចំនួនទឹកប្រាក់រំដោះដែលបានបង់លើស ត្រូវចាត់ទុកជាប្រយោជន៍ថវិការដ្ឋ។

គ.២-ចំពោះផលិតផលរ៉ែ ដូចមានកំណត់នៅចំណុច (ខ, គ, និង ឃ) ប្រការ ២ នៃប្រកាសនេះ÷

គ.២.១-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការផលិតកម្មប្រចាំត្រីមាស ប្ដូកនឹងឥណទានយោង (ប្រសិនបើមាន) តិចជាងថ្លៃសួយសារ តាមបរិមាណដែលផលិត ឬទាញយកបានជាក់ស្ដែងប្រចាំត្រីមាស នោះសម្បទានិកមានកាតព្វកិច្ចត្រូវបង់បង្គ្រប់។

គ.២.២-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការផលិតកម្មប្រចាំត្រីមាស ប្ដូកនឹងឥណទានយោង (ប្រសិនបើមាន) ច្រើនជាងថ្លៃសួយសារ តាមបរិមាណដែលផលិត ឬទាញយកបានជាក់ស្ដែងប្រចាំត្រីមាស ហើយអាជ្ញាបណ្ណធនធានរ៉ែក៏នៅមានសុពលភាព នោះចំនួនទឹកប្រាក់រំដោះដែលបានបង់លើស ត្រូវបានអនុញ្ញាតឱ្យជាឥណទានប្ដូកយោងទៅត្រីមាសបន្ទាប់។

គ.២.៣-ករណីប្រាក់រំដោះ ដែលបានបង់មុនតាមផែនការផលិតកម្មប្រចាំត្រីមាស ប្ដូកនឹងឥណទានយោង (ប្រសិនបើមាន) ច្រើនជាងថ្លៃសួយសារ តាមបរិមាណដែលផលិត ឬទាញយកបានជាក់ស្ដែងប្រចាំត្រីមាស ប៉ុន្តែអាជ្ញាបណ្ណធនធានរ៉ែ ត្រូវបានដកហូត ឬត្រូវបានបញ្ចប់ ឬត្រូវផុតសុពលភាព នោះចំនួនទឹកប្រាក់រំដោះដែលបានបង់លើស ត្រូវចាត់ទុកជាប្រយោជន៍ថវិការដ្ឋ។

គ.៣-ករណីប្រាក់រំដោះសម្រាប់ផលិតផលរ៉ែ ដូចមានកំណត់នៅចំណុច (ក, ខ, គ, និង ឃ) ប្រការ ២ នៃប្រកាសនេះ ដែលបានបង់មុនតាមផែនការផលិតកម្មប្រចាំត្រីមាស ប្ដូកនឹងឥណទានយោង (ប្រសិនបើមាន) តិចជាងថ្លៃសួយសារ តាមបរិមាណដែលផលិត ឬទាញយកបានជាក់ស្ដែងប្រចាំត្រីមាស ហើយសម្បទានិកមិនបានប្រកាស ឬមិនបង់បង្គ្រប់នូវថ្លៃសួយសារដែលខ្វះ តាមការកំណត់នៅចំណុច (គ.១.១) និងចំណុច (គ.២.១) ប្រការ ៤ នៃប្រកាសនេះ សម្បទានិកត្រូវប្រឈមនឹងវិធានការផ្លូវច្បាប់ជាធរមាន។

ឃ-ការប្រកាសសួយសារ ត្រូវរៀបចំតាមទម្រង់បែបបទ កំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ដែលបង្ហាញលំអិតអំពី÷

- បរិមាណផលិតផលរ៉ែ
- កិច្ចព្រមព្រៀង ឬកិច្ចសន្យាលក់ និងព័ត៌មានរបស់ភាគីពាក់ព័ន្ធការទិញលក់ទាំងអស់ (ប្រសិនបើមាន)
- ថ្លៃ ឬថ្លៃមូលដ្ឋានសម្រាប់ការគណនាសួយសារ
- វិក្កយបត្រលក់ សក្ខីបត្រទូទាត់ និងការបញ្ចុះថ្លៃផ្សេងៗ
- វិធីសាស្ត្រ និងរបៀបគណនាសួយសារ និង
- ព័ត៌មានចាំបាច់ផ្សេងៗទៀត។

**ប្រការ ៥.~**

ក្រៅពីកាតព្វកិច្ចបង់សួយសារ សម្បទានិកត្រូវមានកាតព្វកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធដទៃទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៦.~**

ក-កាតព្វកិច្ចហិរញ្ញវត្ថុពាក់ព័ន្ធនឹងអត្រាសួយសារលើតម្លៃផលិតផលរ៉ែ ដែលមានចែងក្នុងកិច្ចព្រមព្រៀង ឬឯកសារផ្សេងៗកន្លងមក ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ លើកលែងតែករណីកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ដែលទទួលបានគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល ឬកាតព្វកិច្ចហិរញ្ញវត្ថុនោះ ជាបដិភាគរបស់រាជរដ្ឋាភិបាល ឬត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ។

ខ-រាល់ការអនុញ្ញាតឱ្យលើកលែងការបង់ថ្លៃសួយសារ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល តាមការពិនិត្យ និងលើកយោបល់ស្នើសុំការពិនិត្យ សម្រេច ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល។

គ-ទោះបីទទួលបានការអនុញ្ញាតលើកលែងការបង់ថ្លៃសួយសារ និង/ឬកាតព្វកិច្ចផ្សេងៗពីរាជរដ្ឋាភិបាល ក៏សម្បទានិកនៅតែមានកាតព្វកិច្ចក្នុងការប្រកាស តាមការកំណត់ក្នុងចំណុច (ឃ) ប្រការ ៤ នៃប្រកាសនេះ។

**ប្រការ ៧.~**

មន្ទីររ៉ែនិងថាមពល ត្រូវធ្វើរបាយការណ៍ អំពីលទ្ធផលនៃការអនុវត្តចំណូលសួយសារប្រចាំត្រីមាស ជូនមកក្រសួងរ៉ែនិងថាមពល និងចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ) ដោយភ្ជាប់មកជាមួយនូវឯកសារបង់ចំណូលទាំងអស់។

**ប្រការ ៨.~**

ដោយផ្អែកលើទិន្នន័យនៃការសិក្សាតម្លៃផលិតផលរ៉ែលើទីផ្សារជាក់ស្តែង និងគុណភាពផលិតផលរ៉ែ ក្រសួងរ៉ែ និងថាមពល ត្រូវធ្វើសន្ទស្សន៍ ស្តីពីស្ថានភាពតម្លៃផលិតផលរ៉ែប្រចាំឆ្នាំ នាអំឡុងខែវិច្ឆិកា។ ទិន្នន័យនេះ គឺជាមូលដ្ឋានសម្រាប់កែសម្រួលអត្រាសួយសារលើតម្លៃផលិតផលរ៉ែ។

តាមការចាំបាច់ ដោយផ្អែកលើទិន្នន័យសន្ទស្សន៍តម្លៃផលិតផលរ៉ែនេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល លើកសំណើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យកែសម្រួលអត្រាសួយសារលើតម្លៃផលិតផលរ៉ែ យ៉ាងយូរ ២ (ពីរ) ឆ្នាំម្តង។

**ប្រការ ៩.~**

ប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០.-**

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ព្រមទាំងសម្បទានិកដូចក្នុងប្រការ១ នៃប្រកាសនេះ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធភាព។

**ប្រការ ១១.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០តទៅ។

ថ្ងៃច័ន្ទ ១១កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ